**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស និងខ្មែរ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៧

**ឯកសារដើម**
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Mar-2017, 13:37
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ: **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការអនុវត្តសំណងតាមផ្លូវតុលាការ សម្រាប់សំណុំរឿង ០០២/០១**

---

**ដាក់ដោយ**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី Laura DESFORGES
ហុង គឹមសួន Ferdinand DJAMMEN NZEPA
គឹម ម៉េងឃី Isabelle DURAND
ឡោ ជុនធី François GAUTRY
ម៉ុច សុវណ្ណារី Emmanuel JACOMY
ស៊ិន សុវ៉ន Martin JACQUIN
សំ សុគង់ Yiqiang Y. LIU
វ៉េន ពៅ Daniel LOSQ
ទី ស្រីណា Christine MARTINEAU
Lyman NGUYEN
Mahesh RAI
Nushin SARKARATI

**នៅចំពោះមុខ**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុល ប្រធាន
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូរ ឧត្តារា
ចៅក្រម Claudia FENZ

**ចែកជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**

ខៀវ សំផន
នួន ជា

**សហមេធាវីការពារក្តី**

សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISS…

**មេធាវីប្រចាំការ**

ទូច វលក្ខណ៍
Calvin SAUNDERS

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

Olivier BAHOUGNE
Patrick BAUDOUIN

## I. សេចក្តីផ្តើម

1. វិធាន ២៣ (១) នៃវិធានផ្ទៃក្នុងផ្តល់សិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំសំណងជាសមូហភាព និងសំណងផ្លូវចិត្តចំពោះព្យសនកម្មដែលពួកគេបានទទួលរងដោយសារលទ្ធផលនៃឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានចោទប្រកាន់។ ក្រោយពេលបញ្ចប់ការដេញដោលលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងអនុលោមតាមវិធាន ២៣*ស្ទួនបួន* នៃវិធានផ្ទៃក្នុង សហមេធាវីនាំមុខបានដាក់សំណើសុំចុងក្រោយស្តីពីសំណងរបស់ខ្លួននៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ ដែលតាមរយៈនោះ សហមេធាវីនាំមុខបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់តាមផ្លូវតុលាការនូវគម្រោងសំណងចំនួន ១៣[1]។

2. នៅក្នុងសាលក្រមលើសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ការផ្តល់សំណងចំនួន ១១ បានបំពេញ "*ទៅតាមលក្ខខណ្ឌតម្រូវដូចមានចែងនៅក្នុងវិធាន ២៣ស្ទួនបួន(៣)(ខ) នៃវិធានផ្ទៃក្នុង ហើយ បានឆ្លើយតបទៅនឹងព្យសនកម្មដែលទទួលរងដោយជនរងគ្រោះ និងផ្តល់សំណងផ្លូវចិត្ត និងជាសមូហភាពដល់ដើមបណ្តឹងរដ្ឋប្បវេណី។ គម្រោងសំណងទាំងអស់នេះមានលក្ខណៈសមស្របអាចធ្វើឱ្យការផ្តល់សំណងដែលសហមេធាវីនាំមុខបានទាមទារនោះមានប្រសិទ្ធភាព និងអាចអនុវត្តបាន*"[2]។

3. ដោយសារការសម្រេចលើពិរុទ្ធភាពបានចូលជាស្ថាពរក្រោយពេលចេញសាលដីកាកាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ រួចហើយនោះ សហមេធាវីនាំមុខសូមដាក់របាយការណ៍នេះដើម្បីជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងសាធារណជនអំពីស្ថានភាពនៃការអនុវត្តគម្រោងសំណងនីមួយៗ។

## II. ស្ថានភាពនៃការអនុវត្តសំណងដែលត្រូវបានទទួលស្គាល់

### ក) និវាជាតិនៃការចងចាំ

4. ក្រោមកិច្ចសហប្រតិបត្តិការជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា គម្រោងមួយនេះមានគោលបំណងកំណត់ទិវាជាតិនៃការចងចាំមួយដែលរាជរដ្ឋាភិបាលទទួលស្គាល់ជាផ្លូវការដើម្បីជាការគោរពដល់ជនរងគ្រោះនៃរបប

---

[1] *សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសំខាត់* ឯកសារ E218/7/6 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣។

[2] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313 កថាខណ្ឌ ១១៥១។

ខ្មែរក្រហម និងទទួលស្គាល់ឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម[3]។

5. នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ សហមេធាវីនាំមុខត្រូវបានជូនដំណឹងតាមរយៈអនុស្សារណៈអន្តរការិយាល័យស្តីអំពីការបញ្ជូនបន្តនូវលិខិតលេខ ១៣១២ ស.ជ.ណ ដែលជាសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីគម្រោងសំណងនានា ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦[4]។ លិខិតនេះបញ្ជាក់ថា "រាជរដ្ឋាភិបាលបានសម្រេច និងឯកភាពជាគោលការណ៍ដូចខាងក្រោម៖ យកថ្ងៃ ២០ ឧសភា រៀបចំពិធីបុណ្យសាធារណៈមិនប្រកាន់សាសនាមួយ ដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាសាធារណជនអាចចូលរួមធ្វើបុណ្យឧទ្ទិសកុសលដល់ វិញ្ញាណក្ខន្ធដល់ជនរងគ្រោះដែលបានបាត់បង់ជីវិតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ"[5]។

6. គម្រោងមួយនេះមិនទាន់អនុវត្តពេញលេញនៅឡើយទេ ដោយកំពង់រងចាំអនុក្រិត្យរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីប្រកាសទទួលស្គាល់ជាផ្លូវការ។

### ខ) ការកសាងបូជនីយដ្ឋាននៅក្នុងរាជធានីភ្នំពេញដើម្បីរំឭកដល់ជនរងគ្រោះនៃការជម្លៀសប្រជាជន ដោយបង្ខំ

7. ដោយមានការគាំទ្រពីស្ថានទូតបារាំងប្រចាំនៅប្រទេសកម្ពុជា និងក្រុមមិត្តភាពបារាំង-កម្ពុជា នៃរដ្ឋសភាបារាំង គម្រោងនេះត្រូវបានវិចិត្រករខ្មែរសញ្ជាតិបារាំងមួយរូបឈ្មោះ សេរា ស្នើសុំឱ្យបង្កើតបូជនីយដ្ឋានមួយដោយមានរូបចម្លាក់មួយចំនួន។ គម្រោងនេះត្រូវបានស្នើសុំឱ្យបង្កើតបូជនីយដ្ឋានមួយនៅរង្វង់មូលស្ពាតចាស់នៅទល់មុខវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនក្នុងរាជធានីភ្នំពេញ។ ទោះបីជាការផ្តល់មូលនិធិត្រូវបានធានាពេញលេញហើយក៏ដោយ ក៏មានការពន្យារពេលផ្សេងៗទៀតទាក់ទិនទៅនឹងការដាក់ឱ្យគម្រោងនេះចេញជារូបរាងជាក់ស្តែង[6]។

---

[3] *សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសំខាត់* ឯកសារ E218/7/6 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ៨២ ដល់ កថាខណ្ឌ ៩០ និងឧបសម្ព័ន្ធ ១៖ ឯកសារគាំទ្រគម្រោងទី ១៖ ទិវាជាតិនៃការចងចាំ ឯកសារ E218/7/6.1.1។

[4] *សូមមើល* ឧបសម្ព័ន្ធ ១។

[5] *សូមមើល* ឧបសម្ព័ន្ធ ១។

[6] *សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសំងាត់* ឯកសារ E218/7/6 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ១០២ ដល់ កថាខណ្ឌ ១១៣ និងឧបសម្ព័ន្ធ ៣៖ ឯកសារគាំទ្រគម្រោងទី ៣៖ បូជនីយដ្ឋានសម្រាប់ជនរងគ្រោះខ្មែរក្រហម - "សម្រាប់អ្នកស្លាប់បាត់បង់ជីវិត" ឯកសារ E218/7/6.1.3។ សូមមើលផងដែរ *ព័ត៌មានបន្ថែមលើកទីពីរ ទៅនឹងសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដោយអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ពន្ធសម្ងាត់។* ឯកសារ E218/7/8 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ

8. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ សហមេធាវីនាំមុខបានសរសេរលិខិតផ្ញើជូនដៃគូអនុវត្តគម្រោងដើម្បីជូនដំណឹងដល់ពួកគេអំពីការចូលជាស្ថាពរនៃសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ហើយក៏បានជម្រាបពួកគេផងដែរថា គម្រោងនេះគឺជាគម្រោងតែមួយគត់ដែលបានជម្រុញដោយអង្គការមិនមែនរដ្ឋាភិបាលដែលពុំទាន់បានអនុវត្តនៅឡើយ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ សហមេធាវីនាំមុខបានទទួលការជូនដំណឹងថា អាជ្ញាធររាជធានីនឹងផ្តល់លិខិតអនុញ្ញាតសាងសង់ នៅក្នុងរយៈពេលប៉ុន្មានសប្តាហ៍ខាងមុខ។ ស្ថានទូតបារាំងបានធានាជូនសហមេធាវីនាំមុខថា ពុំមានឧបសគ្គផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាលរាំងរាដល់ការអនុវត្តគម្រោងនេះឲ្យបានពេញលេញនោះឡើយ។

**គ) វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម**

9. គម្រោងនេះបានបង្កើតឡើងដោយអង្គការចិត្តសង្គមអន្តរវប្បធម៌ដើម្បីផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីរៀបរាប់ និងចងក្រងឯកសារស្តីអំពីបទពិសោធន៍នៃការឈឺចាប់របស់ពួកគេដោយមានការគាំទ្រ និងការជួយជ្រោមជ្រែងពីអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្ត[7]។

10. គម្រោងវិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្មត្រូវបានអនុវត្តពេញលេញហើយ។ តាមរយៈការផ្តល់សំណងនេះ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤៤ នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់ពីវិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្មនេះ។ ការផ្តល់មូលនិធិសម្រាប់គម្រោងនេះត្រូវបានផ្តល់ជូនដោយក្រសួងសហប្រតិបត្តិការណ៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ *Stiftung Kriegstrauma-Therapie* និងប្រទេសអូស្ត្រាលី។

**ឃ. ក្រុមជួយខ្លួនឯងដើម្បីស្តារនីតិសម្បទា**

11. អង្គការចិត្តសង្គមអន្តរវប្បធម៌ក៏បានបង្កើក្រុមជួយខ្លួនឯងដើម្បីស្តារនីតិសម្បទាផងដែរ។ គម្រោងមួយនេះ

---

១៦ និង *ឧបសម្ព័ន្ធ ២ សម្ងាត់៖ ឯកសារបន្ថែមពាក់ព័ន្ធនឹងគម្រោងទីបី៖ ការកសាងស្តូបរំលឹកវិញ្ញាណក្ខន្ធដល់ជនរងគ្រោះនៃរបបខ្មែរក្រហមដោយសិល្បករ SERA* ឯកសារ E218/7/8.1.2 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤។

[7] *សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសំងាត់* ឯកសារ E218/7/6 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ១២៤ ដល់ កថាខណ្ឌ ១៤២ និងឧបសម្ព័ន្ធ ៥ និង ៦៖ ឯកសារគាំទ្រគម្រោងទី ៥ និង ៦៖ វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងក្រុមជួយខ្លួនឯង ឯកសារ E218/7/6.1.5។ សូមមើលផងដែរ *ព័ត៌មានបន្ថែមលើកទីពីរទៅនឹងសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់។* ឯកសារ E218/7/8 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ ២១ និង *ឧបសម្ព័ន្ធ ៤ សម្ងាត់៖* ឯកសារបន្ថែមពាក់ព័ន្ធនឹងគម្រោងទីប្រាំ និងទីប្រាំមួយ៖ វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងក្រុមជួយខ្លួនឯង។ ឯកសារ E218/7/8.1.4។

បានបង្កើតក្រុមជួយខ្លួនឯងដែលមានការជួយសម្រួលពីបុគ្គលិកដែលមានវិជ្ជាជីវៈ និងអនុវត្តនៅតាមមូលដ្ឋានចំនួន ៦ កន្លែង ដែលក្រុមនេះមានសមាសភាពអ្នកស្ម័គ្រចិត្តដើម្បីជួយពួកគេខ្លួនឯង និងជួយគ្នាទៅវិញទៅមកក្នុងការបង្កើនកម្រិតសុខមាលភាព បង្កើតវិធីសាស្រ្ត និងដើម្បជួយគ្នាទៅវិញទៅមកក្នុងការដោះស្រាយ និងព្យាបាលវិបត្តិផ្លូវចិត្ត[8]។

12. គម្រោងនេះត្រូវបានអនុវត្តពេញលេញដោយមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៧៧ រូប បានចូលរួមនៅក្នុងក្រុមជួយខ្លួនឯងនេះ។ គម្រោងនេះអាចបង្កើតឡើងទៅបានដោយសារមានការផ្តល់មូលនិធីពីក្រសួងសហប្រតិបត្តិការណ៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ *Stiftung Kriegstrauma-Therapie* និងប្រទេសអូស្រ្តាលី។

**ខ) ការតាំងពិពណ៌អចិន្ត្រៃយ៍នៅតាមសារមន្ទីរខេត្តមួយចំនួន**

13. ការតាំងពិពណ៌អចិន្ត្រៃយ៍អំពីការផ្លាស់ទីដោយបង្ខំ និងទួលពោធិ៍ជ្រៃត្រូវបានអនុវត្តពេញលេញដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដោយមានការផ្តល់មូលនិធិពីក្រសួងសហប្រតិបត្តិការណ៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់។ គម្រោងនេះរួមមានការតាំងពិពណ៌អចិន្ត្រៃយ៍ចំនួន ៨ (៥)? នៅតាមសារមន្ទីរខេត្តបាត់ដំបង ខេត្តតាកែវ ខេត្តស្វាយរៀង ខេត្តបន្ទាយមានជ័យ ខេត្តព្រះសីហនុ ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តក្រចេះ[9]។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៣ នាក់ ត្រូវបានអញ្ជើញឲ្យមកចូលរួមពិធីសម្ពោធការតាំងពិពណ៌នីមួយៗក្នុងចំណោមការតាំងពិពណ៌ទាំងប្រាំបីនេះ។

---

[8] *សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសំងាត់* ឯកសារ E218/7/6 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ១៤៣ ដល់ កថាខណ្ឌ ១៤៧ និងឧបសម្ព័ន្ធ ៥ និង ៦៖ ឯកសារគាំទ្រគម្រោងទី ៥ និង ៦៖ វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងក្រុមជួយខ្លួនឯង ឯកសារ E218/7/6.1.5។ សូមមើលផងដែរ *ព័ត៌មានបន្ថែមលើកទីពីរទៅនឹងសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ពន្ធសម្ងាត់*។ ឯកសារ E218/7/8 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ ២៧ និង*ឧបសម្ព័ន្ធ ៤ សម្ងាត់៖* ឯកសារបន្ថែមពាក់ព័ន្ធគម្រោងទី៥ និងទី៦៖ វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងក្រុមជួយខ្លួន ឯង។ ឯកសារ E218/7/8.1.4។

[9] *សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសំងាត់* ឯកសារ E218/7/6 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ១៥៩ ដល់ កថាខណ្ឌ ១៧៣ និងឧបសម្ព័ន្ធ ៧ និង ៩៖ ឯកសារគាំទ្រគម្រោងទី ៧ និង ៩៖ ការតាំងពិពណ៌អចិន្ត្រៃយ៍នៅសារមន្ទីរខេត្តចំនួន ៥ និងការកោសលុបជំពូកស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងកាប់សម្លាប់ទួលពោធិ៍ជ្រៃ ឯកសារ E218/7/6.1.6។ សូមមើលផងដែរ *ព័ត៌មានបន្ថែមលើកទីពីរទៅនឹងសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ពន្ធសម្ងាត់*។ ឯកសារ E218/7/8 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ ៣០។

14. ក្រោយពេលចេញសាលដីកាលើសំណុំរឿង ០០២/០១ សហមេធាវីនាំមុខបានសរសេរលិខិតមួយច្បាប់ផ្ញើជូនមជ្ឈមណ្ឌលឯកសារកម្ពុជាដោយបានជម្រាបមជ្ឈមណ្ឌលអំពីការច្រានចោលពិរុទ្ធភាពមួយចំនួន ពីសំណាក់អង្គជំនុំជម្រះតុលាការកំពូល និងបានស្នើឱ្យមជ្ឈមណ្ឌលដាក់បញ្ចូលការបដិសេធទទួលខុសត្រូវលើការតាំងពិពណ៌ និងសម្ភារៈពាក់ព័ន្ធនានាដើម្បីឆ្លុះបញ្ចាំងពិរុទ្ធភាពចុងក្រោយរបស់ជនជាប់ចោទ ដោយសារការតាំងពិពណ៌លើកឡើងហេតុការណ៍នៅទួលពោធិ៍ជ្រៃ និងមានលក្ខណៈអចិន្ត្រៃយ៍[10]។

**ច) ការតាំងពិពណ៌ចល័តស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម និង អ.វ.ត.ក**

15. អង្គការក្តីករុណា និងអង្គការយុវសន្តិភាពបានបង្កើតគម្រោងតាំងពិពណ៌ចល័តតាមប្រព័ន្ធផ្សព្វផ្សាយចម្រុះដើម្បីអប់រំប្រជាជនកម្ពុជាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម អ.វ.ត.ក និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាពិសេសអ្នកទាំងឡាយដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅដោយបង្ខំ។ គម្រោងនេះបានទទួលមូលនិធិពីក្រសួងសហប្រតិបត្តិការណ៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ វិទ្យាស្ថានទំនាក់ទំនងការបរទេសនៃរដ្ឋាភិបាលអាល្លឺម៉ង់ និងក្រុមហ៊ុន Narrowcasters Pty. Limited[11]។

---

[10] ឧបសម្ព័ន្ធ ២ (លិខិតផ្ញើជូនមជ្ឈមណ្ឌលឯកសារកម្ពុជា) ដោយស្នើដាក់បញ្ចូលពាក្យពេចន៍ដូចខាងក្រោមនៅក្នុងសម្ភារៈគម្រោង៖ [*ការតាំងពិពណ៌/សម្ភារៈ*] ជំពូកនេះបានផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនៅចំពោះមុខ អ.វ.ត.ក។ សាលដីកានៅក្នុងសំណុំរឿង ០០២/០១ គឺជាការរៀបរាប់តាមផ្លូវច្បាប់តែមួយគត់អំពីហេតុការណ៍ដូចបានបង្ហាញក្នុង[*ការតាំងពិពណ៌/សម្ភារៈ*]។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ពិរុទ្ធភាពរបស់ នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀតដោយសារវាពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ២។ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាលដោយសារវាពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ១ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយដោយសារវាពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ២ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយដោយសារវាពាក់ព័ន្ធនឹងហេតុការណ៍នៅទួលពោធិ៍ជ្រៃ។ *សូមមើលផងដែរ* សាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313 កថាខណ្ឌ ១១៥៧ និងលេខយោងជើងទំព័រ ៣២៨៦។ ទោះបីជាការអះអាងបដិសេធដូចបានស្នើសុំអនុវត្តចំពោះគម្រោងខុសៗគ្នាក៏ដោយ សហមេធាវីនាំមុខកត់សម្គាល់ឃើញថា ហេតុផលស្រដៀងគ្នាត្រូវយកមកអនុវត្តជាពិសេសដោយសារពិរុទ្ធភាពចំពោះទួលពោធិ៍ជ្រៃត្រូវបានច្រានចោល ហើយការតាំងពិពណ៌ដែលត្រូវបានបង្កើតឡើងតាំងពីមុនពេលមានការប្រកាសសាលដីកាលើសំណុំរឿង ០០២/០១ មកម្ល៉េះនោះ មានលក្ខណៈអចិន្ត្រៃយ៍ ។

[11] *សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសំងាត់* ឯកសារ E218/7/6 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ១៧៤ ដល់ កថាខណ្ឌ ១៨៨ និងឧបសម្ព័ន្ធ ៨៖ ឯកសារគាំទ្រគម្រោងទី ៨៖ ការតាំងពិពណ៌ចល័តស្តីពីការជម្លៀសប្រជាជនដោយបង្ខំ ឯកសារ E218/7/6.1.7។ សូមមើលផងដែរ *ព័ត៌មានបន្ថែមលើកទីពីរទៅនឹងសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន*

16. គម្រោងនេះត្រូវបានអនុវត្តពេញលេញដោយមានការតាំងពិពណ៌នៅតាមទីតាំងចំនួន ១២ កន្លែង[12]។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១៧ នាក់ត្រូវបានអញ្ជើញឱ្យមកចូលរួមនៅក្នុងពិធីសម្ពោធការតាំងពិពណ៌នេះ។

**ឆ) ជំពូកស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទួលពោធិ៍ជ្រៃនៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន**

17. មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតជំពូកមួយបន្ថែមស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ នៅក្នុងសៀវភៅណែនាំរបស់គ្រូបង្រៀន ដើម្បីដាក់ជាគម្រោងសំណងចំពោះដើមបណ្តឹងរដ្ឋប្បវេណី៖ ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩) ដែលត្រូវបានប្រើប្រាស់នៅក្នុងកម្មវិធីអប់រំទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ គម្រោងនេះបានទទួលមូលនិធិពីសេវាសន្តិភាពពលរដ្ឋនៃ *Deutsche Gesellschaft Fuer International Zusammenarbeit* (GIZ) និងក្រសួងសហប្រតិបត្តិការណ៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់[13]។

18. គម្រោងនេះត្រូវបានអនុវត្តពេញលេញតាមរយៈការបោះពុម្ពផ្សាយសារជាថ្មីនូវសៀវភៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយការបណ្តុះបណ្តាលគ្រូបង្រៀនកំពុងដំណើរការ។ រឿងរ៉ាវផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤ នាក់ត្រូវបានដាក់បញ្ចូលនៅក្នុងជំពូកនេះ។

19. បន្ទាប់ពីការប្រកាសសាលដីកាលើសំណុំរឿង ០០២/០១ រួចមក សហមេធាវីនាំមុខបានសរសេរលិខិតមួយ

---

*៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ពន្ធសម្ងាត់*។ ឯកសារ E218/7/8 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ ៣២ ដល់ កថាខណ្ឌ ៣៤ និង*ឧបសម្ព័ន្ធ ៥ សម្ងាត់*៖ ឯកសារបន្ថែមពាក់ព័ន្ធនឹងគម្រោងទីប្រាំបី៖ ការតាំងពិព័រណ៍អចិន្ត្រៃយ៍ ឯកសារ E218/7/8.1.5។

[12] ទីតាំងនានារួមមាន៖ ខេត្តកំពត ខេត្តស្ទឹងត្រែង ខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ ខេត្តត្បូងឃ្មុំ ខេត្តរតនៈគិរី ខេត្តកំពង់ធំ ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល និងខេត្តស្វាយរៀង។

[13] *សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសំងាត់* ឯកសារ E218/7/6 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ១៨៩ ដល់ កថាខណ្ឌ ១៩៨ និងឧបសម្ព័ន្ធ ៧ និង ៩៖ ឯកសារគាំទ្រសម្រាប់គម្រោងទី ៧ និង ៩៖ ការតាំងពិពណ៌អចិន្ត្រៃយ៍នៅសារមន្ទីរខេត្តចំនួន ៥ និងការកោសលុបជំពូកស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងកាប់សម្លាប់ទួលពោធិ៍ជ្រៃ ឯកសារ E218/7/6.1.6។ សូមមើលផងដែរ *ព័ត៌មានបន្ថែមលើកទីពីរទៅនឹងសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ពន្ធសម្ងាត់*។ ឯកសារ E218/7/8 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ ៣៨ ដល់ កថាខណ្ឌ ៤០ និង*ឧបសម្ព័ន្ធ ៦ សម្ងាត់*៖ ឯកសារបន្ថែមពាក់ព័ន្ធនឹងគម្រោងទីប្រាំបួន ៖ ការតាក់តែងជំពូកជាក់លាក់ ពាក់ព័ន្ធទៅនឹងការជម្លៀសមនុស្សដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិជ្រៃ។ ឯកសារ E218/7/8.1.6។

ច្បាប់ផ្ញើជូនមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីជូនដំណឹងអំពីការច្រានចោលពិរុទ្ធភាពមួយចំនួន ហើយបានស្នើឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការដាក់បញ្ចូល សេចក្តីបដិសេធទទួលខុសត្រូវចំពោះជំពូកនេះដើម្បីឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវលើការសម្រេចអំពីពិរុទ្ធភាពស្ថាពររបស់ជនជាប់ចោទ[14]។

**ខ) មជ្ឈមណ្ឌលសិក្សាសន្តិភាពនៅសំរោងក្នុង**

20. សម្រាប់គម្រោងសំណងមួយនេះ អង្គការយុវសន្តិភាពបានសាងសង់ និងកំពុងថែទាំមជ្ឈមណ្ឌលសិក្សាសន្តិភាពមួយនៅភូមិសំរោងក្នុង ខេត្តបាត់ដំបង នៅត្រង់ទីតាំងប្រវត្តិសាស្ត្រមួយកន្លែងដែលជាទីកន្លែងកើតមានការកាប់សម្លាប់ទ្រង់ទ្រាយធំក្នុងរបបខ្មែរក្រហម។ មជ្ឈមណ្ឌលសិក្សាសន្តិភាពនេះរួមមានមណ្ឌលព័ត៌មាន សារមន្ទីរ និងបន្ទប់សន្ទនា[15]។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០ នាក់ត្រូវបានអញ្ជើញឲ្យមកចូលរួមវេទិការដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅទីនោះ ពួកគាត់ត្រូវបានផ្តល់ឱកាសឲ្យចែករំលែកបទពិសោធន៍របស់ពួកគាត់ក្នុងសម័យខ្មែរក្រហម និងបទពិសោធន៍ពាក់ព័ន្ធនឹងការចូលរួមរបស់ពួកគាត់នៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះលើសំណុំរឿង ០០២/០១។ មិនតែប៉ុណ្ណោះ ដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមក្នុងដំណើរការធ្វើឲ្យធូរស្បើយ និងការរៀបរាប់អំពីការពិតតាមរយៈកិច្ចសន្ទនា សិល្បៈ ពិធីបុណ្យតាមបែបពុទ្ធសាសនា និង

---

[14] ឧបសម្ព័ន្ធ 2 (លិខិតផ្ញើជូនមជ្ឈមណ្ឌលឯកសារកម្ពុជា) ដោយស្នើដាក់បញ្ចូលពាក្យពេចន៍ដូចខាងក្រោមនៅក្នុងសម្ភារៈគម្រោង៖ ជំពូកនេះបានផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនៅចំពោះមុខ អ.វ.ត.ក។ សាលដីកានៅក្នុងសំណុំរឿង ០០២/០១ គឺជាការរៀបរាប់តាមផ្លូវច្បាប់តែមួយគត់អំពីហេតុការណ៍ដូចបានបង្ហាញក្នុងជំពូកនេះ។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ពិរុទ្ធភាពរបស់ នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀតដោយសារវាពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ២។ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ដោយសារវាពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ១ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយដោយសារវាពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ២ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយដោយសារវាពាក់ព័ន្ធនឹងហេតុការណ៍នៅទួលពោធិ៍ជ្រៃ។ *សូមមើលផងដែរ* សាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313 កថាខណ្ឌ ១១៥៧ និងលេខយោងជើងទំព័រ ៣២៩៦។

[15] *សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសំងាត់* ឯកសារ E218/7/6 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ១៩៩ ដល់ កថាខណ្ឌ ២១១ និងឧបសម្ព័ន្ធ ១០ សម្ងាត់៖ ឯកសារគាំទ្រសម្រាប់គម្រោងទី ១០៖ មជ្ឈមណ្ឌលសិក្សាសន្តិភាពនៅសំរោងក្នុង ឯកសារ E218/7/6.1.8។ សូមមើលផងដែរ *ព័ត៌មានបន្ថែមលើកទីពីរទៅនឹងសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ពន្ធសម្ងាត់*។ ឯកសារ E218/7/8 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ ៤១ និង*ឧបសម្ព័ន្ធសម្ងាត់ទី ៧ ៖* ឯកសារបន្ថែមពាក់ព័ន្ធទៅនឹងគម្រោងទីដប់៖ ការបង្កើតមជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍។ ឯកសារ E218/7/8.1.7។

ការចងក្រងឯកសារពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្ម។

21. គម្រោងនេះត្រូវបានអនុវត្តពេញលេញ ហើយសកម្មភាពនានាកំពុងដំណើរការ។ គម្រោងនេះអាចអនុវត្តទៅបានដោយសារការផ្តល់មូលនិធិពីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការណ៍។

**ឈ. គម្រោងរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី - សៀវភៅគំនូររឿងរ៉ាវជនរងគ្រោះក្នុងរបបខ្មែរក្រហមដែលបានចូលរួមនៅ អ.វ.ត.ក**

22. អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) បានបោះពុម្ពនូវសៀវភៅរឿងរ៉ាវផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីដាក់ជាគម្រោងសំណងមួយ។ គម្រោងនេះមានបំណងប្រែក្លាយដើមបណ្តឹងរដ្ឋប្បវេណីឲ្យទៅជាអ្នកនិទានរឿងដោយផ្តល់ឱកាសឲ្យពួកគេរៀបរាប់រឿងរ៉ាវរបស់ខ្លួន ទាំងនៅក្នុងទម្រង់និទានជាលាយលក្ខណ៍អក្សរ និងគំនូរ។ គម្រោងនេះបានទទួលមូលនិធិពីសេវាសន្តិភាពពលរដ្ឋនៃ *Deutsche Gesellschaft Fuer International Zusammenarbeit* (GIZ) និងក្រសួងសហប្រតិបត្តិការណ៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់[16]។

23. គម្រោងនេះត្រូវបានអនុវត្តពេញលេញដោយមានការបោះពុម្ពផ្សាយសៀវភៅចំនួន ២០៣០ ក្បាល ហើយសៀវភៅចំនួន ១២៧០ ក្បាល ត្រូវបានចែកជូនដល់ដើមបណ្តឹងរដ្ឋប្បវេណី និងនៅតាមសាលារៀន។ រឿងរ៉ាវផ្ទាល់ខ្លួន និងរឿងនិទានរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៩ នាក់ត្រូវបានដាក់បញ្ចូលនៅក្នុងសៀវភៅនេះ។

**៣) ការបោះពុម្ពផ្សាយសាលក្រម**

24. អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះ និងផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក បានស្នើដាក់ជាគម្រោងសំណង នូវសកម្មភាពនៃការចែកជូនដើមបណ្តឹងរដ្ឋប្បវេណីនូវសាលក្រមសំណុំរឿង ០០២/០១ ដែលបានបោះពុម្ពផ្សាយក្នុងទម្រង់សង្ខេប និងទម្រង់ទាំង

[16] *សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសំងាត់* ឯកសារ E218/7/6 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ២១២ ដល់ កថាខណ្ឌ ២២១ និងឧបសម្ព័ន្ធ ១១ សម្ងាត់៖ ឯកសារគាំទ្រសម្រាប់គម្រោងទី ១១៖ រឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី - សៀវភៅគំនូរនៃជនរងគ្រោះសម័យខ្មែរក្រហមដែលបានចូលរួមនៅ អ.វ.ត.ក E218/7/6.1.10។ សូមមើលផងដែរ *ព័ត៌មានបន្ថែមលើកទីពីរទៅនឹងសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសម្ងាត់*ឯកសារ E218/7/8 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ ៤៣។

មូល[17]។ គម្រោងនេះត្រូវបានអនុវត្តពេញលេញហើយ។ សាលក្រមត្រូវបានចែកជូនដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៣៥២២ នាក់ នៅក្នុងអំឡុងវេទិកាដើមបណ្តឹងរដ្ឋប្បវេណី និងនៅខណៈពេលដើមបណ្តឹងរដ្ឋប្បវេណី មកទស្សនកិច្ចនៅតុលាការដើម្បីចូលរួមកិច្ចដំណើរការនីតិវិធី[18]។

**ង) ការបោះពុម្ពផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី**

25. អ.វ.ត.ក បានបោះពុម្ពផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ និងព័ត៌មានមូលដ្ឋានស្តីពីអត្តសញ្ញាណ របស់ពួកគេនៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០១ ហើយនឹងនៅលើគេហទំព័រនៃ អ.វ.ត.ក ដើម្បីជាមធ្យោបាយមួយក្នុងការទទួលស្គាល់ព្យសនកម្មដែលដើម បណ្តឹងរដ្ឋប្បវេណីបានទទួលរង និងដើម្បីទទួលស្គាល់ការចូលរួមរបស់ពួកគេនៅក្នុងកិច្ចដំណើរការនីតិវិធី[19]។ គម្រោងនេះត្រូវបានអនុវត្តពេញលេញហើយ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ | ពេជ អង្គ<br>សហមេធាវីនាំមុខ | រាជធានីភ្នំពេញ |  |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | រាជធានីភ្នំពេញ |  |

[17] *សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសំងាត់* ឯកសារ E218/7/6 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ២២៣ ដល់ កថាខណ្ឌ ២២៦ និងឧបសម្ព័ន្ធ ១២ និង ១៣ សម្ងាត់៖ ឯកសារគាំទ្រសម្រាប់គម្រោងទី ១២ និង ១៣៖ ការបោះពុម្ពផ្សាយសាលក្រម និងការបោះពុម្ពផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E218/7/6.1.9។ សូមមើលផងដែរ *ព័ត៌មានបន្ថែមលើកទីពីរទៅនឹងសំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨០ ស្ទួន នៃវិធានផ្ទៃក្នុង និងឧបសម្ពន្ធសម្ងាត់* ។ ឯកសារ E218/7/8 ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ ៤៩ ដល់ កថាខណ្ឌ ៥០ និង*ឧបសម្ព័ន្ធ ៨ សម្ងាត់៖* ឯកសារបន្ថែមពាក់ព័ន្ធនឹងគម្រោងទី ១២៖ ការបោះពុម្ព និងការចែកផ្សាយសាលក្រមទាំងមូល និងជាសង្ខេប។ ឯកសារ E218/7/8.1.8។

[18] សូមពិនិត្យមើលឧបសម្ពន្ធ ៣.៨ អ.វ.ត.ក - ការចែកចាយសាលក្រម បញ្ជីដែលផ្តល់ជូនដោយអង្គភាពគាំពារជនរងគ្រោះ។

[19] *សំណើសុំចុងក្រោយស្តីពីសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ ស្ទួននៃវិធានផ្ទៃក្នុង និងឧបសម្ព័ន្ធសំងាត់* ឯកសារ E218/7/6 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ២២៧ ដល់ កថាខណ្ឌ ២២៩ និងឧបសម្ព័ន្ធ ១២ និង ១៣ សម្ងាត់៖ ការបោះពុម្ពផ្សាយសាលក្រម និងការបោះពុពផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E218/7/6.1.9។